ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

Nº ១៤២ MEF/...........

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ការរៀបចំសមាសភាពគណៈកម្មការចំរុះ
## អន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ

**************

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ : នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខៈ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ : ១០ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/១២៩៩/១៩ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ :នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ : ៨៦ សសរ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងទទួលបន្ទុករៀបចំដាក់ផ្សាយប័ណ្ណរតនាគារ
- បានឃើញអនុក្រឹត្យលេខ : ០៨ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការដាក់ផ្សាយប័ណ្ណរតនាគារ
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ : ០៨ សសរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ

## សំរេច

**ប្រការ១** : ត្រូវបានរៀបចំសមាសភាពគណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ ដូចខាងក្រោម :

១- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រធាន

២- ឯកឧត្តម **នេះ ថ្លាយសាន** ទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា ជាអនុប្រធាន

៣- ឯកឧត្តម **ជុំ គឹមឡេង** អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ជាសមាជិកអចិន្ត្រៃយ៍

៤- លោក **ខិន ឃន** ប្រធានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៥- លោក **រត្ន័ សារុន** ប្រធាននាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា ជាសមាជិក

៦- លោក **ម៉ី ទាវ៉ាន់** ប្រធាននាយកដ្ឋានឧស្សាហកម្ម ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៧- លោក **នួច ឡេង** ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៨- លោក **ជា ចន្ទណា** ប្រធាននាយកដ្ឋានវិភាគនិងព្យាករណ៍សេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក ។

**ប្រការ២**: គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ ត្រូវយកការិយាល័យគ្រប់គ្រងប័ណ្ណរតនាគារនៃរតនាគារជាតិធ្វើជាលេខាធិការដ្ឋាន ។

**ប្រការ៣**: គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ មានភារកិច្ចកំណត់អត្រាការប្រាក់ កាលវសាន ចំនួនទឹកប្រាក់នៃការដាក់ផ្សាយលក់ប័ណ្ណរតនាគារមួយលើក ។ និង តំលៃនៃការបោះផ្សាយប័ណ្ណរតនាគារនីមួយ ។ ព្រមទាំងដំណើរការនៃកិច្ចប្រតិបត្តិការរៀបចំបោះផ្សាយប័ណ្ណរតនាគាររបស់រដ្ឋ ។

**ប្រការ៤**: ប្រធានគណៈកម្មការចំរុះមានសិទ្ធិកោះអញ្ជើញអនុប្រធាន និង សមាជិកចូលរួមប្រជុំតាមការចាំបាច់ដើម្បី

ដំណើរការដាក់ផ្សាយប័ណ្ណរតនាគារ ។ ក្នុងករណីប្រធានគណៈកម្មការអវត្តមាន អនុប្រធានគណៈកម្មការ មានសិទ្ធិកោះអញ្ជើញសមាជិកនៃគណៈកម្មការចូលរួមប្រជុំតាមការចាំបាច់ជំនួសប្រធាន ។

**ប្រការ៥:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ ក្នុងប្រការ ១ ខាងលើ និង អង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា មានភារកិច្ចអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ